មាត្រា៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាទេះតទៅ ។

ភ្នំពេញ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

***

**ព្រះរាជក្រឹត្យ នស/រកត/០៤០១/០៨៥**

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦នស/៩៤ ចុះថ្ងៃទី ៣០ខែ តុលា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រី រាជការស៊ីវិលនៃព្រះរាជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ០២ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការ អន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់នាយករដ្ឋមន្ត្រី និងដោយមានការឯកភាពពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំពេញអង្គ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០១

Downloaded from http://www.khmerlaws.com

# ប្រកាសបន្ទាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-** ត្រូវបានបង្កើតក្របខ័ណ្ឌមន្ត្រីការទូត ជាន់ខ្ពស់របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដែលត្រូវបានចាត់ថ្នាក់ចូលក្នុងប្រភេទ ក ដូចមានចែងក្នុងមាត្រា ៣ នៃព្រះរាជក្រឹត្យលេខ ជស/រកត/ ១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃ ការរៀបចំមុខ ងារសាធារណៈរបស់រដ្ឋ ។

**មាត្រា២.-** មន្ត្រីរាជការនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នេះត្រូវស្ថិតនៅក្រោមឱវាទ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា៣.-** មន្ត្រីរាជការនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ មានភារកិច្ចក្នុងការរៀបចំ និងអនុវត្តគោលនយោបាយរាជរដ្ឋាភិបាល ក្នុងសមត្ថកិច្ចរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ព្រមទាំងធានាដល់ការដឹកនាំគ្រប់គ្រងអង្គភាពនានានៅក្នុងក្រសួង និងនៅស្ថានតំណាងនានានៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ។

មន្ត្រីរាជការនៃក្របខ័ណ្ឌនេះ មានឧបនិស្ស័យក្នុងការបំពេញមុខងារក្នុងតំណែងដឹកនាំអធិការកិច្ចសិក្សា និងផ្តល់យោបល់ និងរាល់តំណែងទទួលខុសត្រូវ ។

## ជំពូកទី ២

## ឋានន្តរស័ក្តិនិងមុខតំណែងក្របខ័ណ្ឌ

**មាត្រា៤ .-** ក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់មាន ៣ ឋានន្តរស័ក្តិ :

- ឧត្តមមន្ត្រីការបរទេស មាន ៦ថ្នាក់
- វរៈមន្ត្រីការបរទេស មាន ១០ថ្នាក់
- អនុមន្ត្រីការបរទេស មាន ១៤ ថ្នាក់ ។

**មាត្រា៥ .-** មន្ត្រីរាជការក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រីការបរទេស មានឧបនិស្ស័យសំរាប់កាន់មុខតំណែងនៅក្រសួង ក្នុងប្រទេសជា:

- អគ្គលេខាធិការ
- អគ្គនាយក
- អគ្គាធិការ

Downloaded from http://www.khmerlaws.com

- និងមុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុង អង្គការលេខនៃរចនាសម្ព័ន្ធរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

មន្ត្រីរាជការក្នុងឋានន្តរស័ក្តិ វរៈមន្ត្រីការបរទេស មានឧបនិស្ស័យសំរាប់កាន់មុខ តំណែង ទាក្រសួងក្នុងប្រទេសជា :

- អគ្គនាយករង
- អគ្គាធិការរង
- ប្រធាននាយកដ្ឋាន

- និងមុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុង អង្គការលេខនៃរចនាសម្ព័ន្ធរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

មន្ត្រីរាជការក្នុងឋានន្តរស័ក្តិ អនុមន្ត្រីការបរទេស មានឧបនិស្ស័យសំរាប់កាន់មុខ តំណែងនៅក្រសួងក្នុងប្រទេសជា:

- អនុប្រធាននាយកដ្ឋាន
- និងមុខតំណែងឯទៀតដែលមានថ្នាក់ស្មើនិងមុខតំណែងខាងលើ ដែលមាននៅក្នុង អង្គការលេខនៃរចនាសម្ព័ន្ធរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា៦.-** មន្ត្រីរាជការនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ មានឧបនិស្ស័យសំរាប់កាន់មុខ តំណែងនៅស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេសជា :

- ឯកអគ្គរាជទូត អគ្គរាជទូត សំរាប់ឋានន្តរស័ក្តិឧត្តមមន្ត្រីការបរទេស
- អគ្គទីប្រឹក្សា ទីប្រឹក្សា អគ្គកុងស៊ុល សំរាប់ឋានន្តរស័ក្តិវរៈមន្ត្រីកាបរទេស
- លេខាធិការទី១កុងស៊ុល លេខាធិការទី២ លេខាធិការទី៣ អនុកុងស៊ុល សំរាប់ឋានន្តរស័ក្តិ អនុមន្ត្រីការបរទេស ។

## ជំពូកទី ៣

## ការជ្រើសរើស

**មាត្រា៧.-** ការជ្រើសរើសបញ្ចូលក្នុងក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ត្រូវធ្វើឡើងតាមរយៈការប្រឡងប្រជែងក្នុងចំណោមបេក្ខជនជាមន្ត្រីរាជការនិង ឬក្នុងចំណោមនិស្សិត ។ ចំនួនតំណែងក្នុងការជ្រើសរើស

Downloaded from http://www.khmerlaws.com

សំរាប់បេក្ខជនជាមន្ត្រីរាជការ និងសំរាប់បេក្ខជនជានិស្សិតត្រូវកំណត់ដោយរាជរដ្ឋាភិបាល តាមសំណើរ របស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា៨.-** ការប្រឡងប្រជែងក្នុងចំណោមនិស្សិត ត្រូវធ្វើចំពោះបេក្ខជនដែលមានសញ្ញាប័ត្រទាបបំផុត បរិញ្ញាប័ត្រ ឬសញ្ញាប័ត្រដែលមានតំលៃស្មើ ហើយដែលមានអាយុច្រើបំផុត ៣០ឆ្នាំ គិតមកដល់ថ្ងៃ ប្រឡង ។

ការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការផ្ទៃក្នុង ត្រូវធ្វើចំពោះមន្ត្រីរាជការ ដែលស្ថិតយ៉ាង ទាបបំផុតក្នុងថ្នាក់លេខ១១របស់ក្របខ័ណ្ឌប្រភេទ ខ និងមានអាយុច្រើនបំផុត ៤៥ ឆ្នាំ ។

ចំពោះមន្ត្រីរាជការរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ដែលមានសញ្ញាប័ត្រ សមមូលនិងសញ្ញាប័ត្រអាចប្រឡងចូលក្របខ័ណ្ឌនេះបានដោយពុំគិតល័ក្ខខ័ណ្ឌ ឋានន្តរស័ក្តិ និង ប្រភេទក្របខ័ណ្ឌឡើយ ហើយមានអាយុយ៉ាងច្រើនបំផុត ៤៥ ឆ្នាំ ។

ការបណ្តុះបណ្តាលដំបូង ត្រូវធ្វើតាមរយៈសាលាភូមិន្ទរដ្ឋបាល ។

## ជំពូកទី ៤

## កម្មសិក្សា និង ការតាំងស៊ប់

**មាត្រា ៩.-** បន្ទាប់ពីការបណ្តុះបណ្តាលដំបូង សិស្សមន្ត្រីការទូតជាន់ខ្ពស់ត្រូវបានចាត់អោយបំរើការងារ នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ហើយត្រូវបានតែងតាំងជាមន្ត្រីការទូតជាន់ ខ្ពស់កម្មសិក្សា ដោយប្រកាសរបស់ក្រសួងការបរទេស និសហប្រតិបត្តិការអន្តរជាតិ ។

មន្ត្រីកម្មសិក្សាទាំងនេះត្រូវឆ្លងកាត់កម្មសិក្សាមួយ ដែលមានរយៈពេល ដូចខាងក្រោម :

១-១២ ខែ ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញពី និស្សិត ។

២-៦ខែ ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញពីមន្ត្រីរាជការដែលពុំស្ថិតក្នុងក្រប ខ័ណ្ឌមន្ត្រីក្រមការបរទេស ។

ចំពោះមន្ត្រីដែលត្រូវបានជ្រើសរើសចេញពីមន្ត្រីរាជការដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីក្រមការការបរទេ សពុំចាំបាច់ឆ្លងកាត់ កម្មសិក្សាឡើយ ។

ក្រោយពេលធ្វើកម្មសិក្សា មន្ត្រីដែលចែងក្នុងចំណុចទី ១ និងទី ២ ខាងលើ ដែលធ្វើកម្មសិក្សាបានល្អ ត្រូវបានតាំងស៊ប់ក្នុងឋានន្តរស័ក្តិ អនុមន្ត្រីការបរទេស ។

ក្នុងករណីចាំបាច់ អាចតម្រូវអោយបន្តការសិក្សាបន្ថែមទៀត ដែលមានរយៈពេលអតិបរមាត្រឹម ១២ ខែ ចំពោះមន្ត្រីដែលមានចែងក្នុងចំណុច ទី ១ និង ៦ខែចំពោះមន្ត្រី ដែលមានចែងក្នុងចំណុច ទី២ ។

Downloaded from http://www.khmerlaws.com

មន្ត្រីដែលពុំបានទទួលជោគជ័យក្នុងការបំពេញកម្មសិក្សាបន្ថែមនេះ ត្រូវលុបឈ្មោះចេញ ប្រសិនបើចេញពីនិស្សិត ឬ មួយត្រូវបញ្ចូលទៅក្នុងក្របខ័ណ្ឌដើមវិញ ប្រសិនបើចេញពីមន្ត្រីរាជការដោយគិតបញ្ចូលសំរាប់អតីតភាពការងារ ។ ករណីខាងលើទាំងនេះត្រូវសំរេចដោយប្រកាសរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ហើយត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរ ៣ ខែ ក្រោយការបញ្ចប់កម្មសិក្សា ។

មន្ត្រីការទូតជាន់ខ្ពស់ ដែលត្រូវបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមនិស្សិត ត្រូវបញ្ចូលទៅក្នុងថ្នាក់លេខ ១៤ នៃឋានន្តរស័ក្តិ អនុមន្ត្រីការបរទេស ។

មន្ត្រីការទូតជាន់ខ្ពស់ ដែលត្រូវបានជ្រើសរើសតាមការប្រឡងប្រជែងក្នុងចំណោមមន្ត្រីរាជការ ត្រូវបញ្ចូលទៅក្នុងថ្នាក់ដែលមានសន្ទស្សន៍បៀវត្សខ្ពស់ លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់សាមីខ្លួននៅពេលប្រឡងជាប់ ។

ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិ អនុមន្ត្រីការបរទេស នៃក្របខ័ណ្ឌ មន្ត្រីការទូតជាន់ខ្ពស់ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ ។

## ជំពូកទី ៥

## ការតែងតាំង

**មាត្រា ១០.-** ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងឋានន្តរស័ក្តិមួយរួចហើយ មន្ត្រីការទូតជាន់ខ្ពស់ទាំងនេះ

អាចត្រូវ

បានតែងតាំងក្នុងមុខតំណែងទំនេរណាមួយដូចមានចែងក្នុងមាត្រា៥ និងមាត្រា៦ ខាងលើ ស្របតាមឋានន្តរស័ក្តិរបស់ខ្លួន តាមបែបបទដូចបានកំណត់ តាមមាត្រា ១៤ និងមាត្រាបន្តបន្ទាប់នៃព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ។

## ជំពូកទី ៦

## ការតម្លើងថ្នាក់ និង ការតម្លើងឋានន្តរស័ក្តិ

**មាត្រា ១១.-** មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ត្រូវបានតម្លើងថ្នាក់ទៅតាមល័ក្ខខ័ណ្ឌដូចបានចែងក្នុងមាត្រា២០ និងមាត្រាបន្តបន្ទាប់នៃច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។

លក្ខណៈសម្បត្តិជាមូលដ្ឋានដែលត្រូវពិនិត្យតម្លើងថ្នាក់ មានដូចខាងក្រោម ៖

១- មានគំនិតផ្តួចផ្តើម និងច្នៃប្រឌិត

Downloaded from http://www.khmerlaws.com

២- មានចំណេះភាសាបរទេស ច្បាស់លាស់

៣- មានស្មារតីទទួលខុសត្រូវ

៤- មានប្រសិទ្ធភាពក្នុងការដឹកនាំ

៥- យកចិត្តទុកដាក់ដល់ផលប្រយោជន៍ជាតិ និងដល់កិត្តិយសក្រសួង

៦- មានសីលធម៌ល្អ ។

ការតម្លើងថ្នាក់នៃមន្ត្រីរាជការក្នុងក្របខ័ណ្ឌនេះ ត្រូវគិតក្នុងសមាមាត្រ បីភាគបួន តាមវេនជ្រើសរើស និងមួយភាគបួនតាមវេនអតីតភាព ។

ចំពោះការតម្លើងថ្នាក់ :

- ការតម្លើងថ្នាក់នៅក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រីការបរទេស ត្រូវសំរេចដោយព្រះរាជក្រឹត្យ
- ការតម្លើងថ្នាក់នៅក្នុងឋានន្តរស័ក្តិ វរៈមន្ត្រីការបរទេស ត្រូវសំរេចដោយអនុក្រឹត្យ

ការតម្លើងថ្នាក់នៅក្នុងឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ត្រូវសំរេចដោយប្រកាសរបស់ក្រសួងការបរទេស និងសហប្រតិបត្តិអន្តរជាតិ ។

**មាត្រា ១២.-** គោលការណ៍នៃការតម្លើងឋានន្តរស័ក្តិតាមធម្មតា ត្រូវតម្លើងថ្នាក់ដំបូងនៃឋានន្តរស័កខ្ពស់លើបន្ទាប់ ឬក្នុងករណីចាំបាច់ ត្រូវតម្លើងទៅក្នុងថ្នាក់ ដែលស្របជាមួយសន្ទស្សន៍ខ្ពស់លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី ។

ការតម្លើងឋានន្តរស័ក្តិ ត្រូវអនុវត្តអោយបានស្របជាមួយចំនួនតំណែងដែលទំនេរនៅក្នុងឋានន្តរស័ក្តិនោះ ហើយត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរស័ក្តិ ឬតាមរយៈការប្រឡងប្រជែង ឬមួយតាមរយៈការបណ្តុះបណ្តាលរយៈពេលវែង នៅក្នុងឬក្រៅប្រទេស ។

ការតម្លើងឋានន្តរស័ក្តិពី អនុមន្ត្រីការបរទេស ទៅវរៈមន្ត្រីការបរទេស ត្រូវសំរេចដោយអនុក្រឹត្យ ហើយការតម្លើងឋានន្តរស័ក្តិ ពីវរៈមន្ត្រីការបរទេស ទៅឧត្តមមន្ត្រីការបរទេស ត្រូវសំរេចដោយព្រះរាជក្រឹត្យ ។

**មាត្រា១៣.-** អាចតម្លើងទៅក្នុងឋានន្តរស័ក្តិ វរៈមន្ត្រីការបរទេស គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ១១ នៃឋានន្តរស័ក្តិអនុមន្ត្រីការបរទេស ។

អាចតម្លើងទៅក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រីការបរទេស គឺមន្ត្រីទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ៧ នៃឋានន្តរស័ក្តិវរៈមន្ត្រីការបរទេស ។

តម្លើងទៅក្នុងឋានន្តរស័ក្តិមួយខ្ពស់ជាង អាចផ្តល់ឧបនិស្ស័យដល់មន្ត្រីសាមីសំរាប់ កាន់មុខតំណែងស្របតាមឋានន្តរស័ក្តិថ្មីនោះ ដូចបានកំណត់ក្នុងមាត្រា៥ និងមាត្រា៦ នៃលក្ខន្តិកៈដោយឡែកនេះ ។

Downloaded from http://www.khmerlaws.com

**មាត្រា ១៤.-** សន្ទស្សន៍សំរាប់ថាក្តក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់និងតំលៃឯកតានៃ សន្ទស្សន៍ ព្រមទាំងរបបលាភការផ្សេងៗទៀត ត្រូវកំណត់ដោយព្រះរាជក្រឹត្យមួយដោយឡែក ។

## ជំពូកទី ៧

## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៥.-** អាណត្តិបំរើការងារនៃមន្ត្រីការទូតជាន់ខ្ពស់នៅបរទេស ត្រូវកំណត់រយៈពេលបីឆ្នាំ ។ ក្នុងករណីចាំបាច់អាណត្តិនេះ អាចពន្យារបានមួយឆ្នាំម្តង តែមិនត្រូវលើសពីរយៈពេលបីឆ្នាំឡើយ ។

**មាត្រា ១៦.-** មន្ត្រីការទូតជាន់ខ្ពស់ បំរើការងាររហូតដល់អាយុ ៦០ ឆ្នាំទើបចូលនិវត្តន៍ ។

ចំពោះការដាក់អោយចូលនិវត្តន៍ :

- ការដាក់អោយចូលនិវត្តន៍នៅក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រីការបរទេស ត្រូវសំរេចដោយព្រះរាជក្រឹត្យ ។
- ការដាក់អោយចូលនិវត្តន៍នៅក្នុងឋានន្តរស័ក្តិ វរៈមន្ត្រីការបរទេស ត្រូវសំរេចដោយអនុក្រឹត្យ
- ការដាក់អោយចូលនិវត្តន៍នៅក្នុងឋានន្តរស័ក្តិ អនុមន្ត្រីការបរទេស ត្រូវសំរេចដោយប្រកាសរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ១៧-** មន្ត្រីការទូតជាន់ខ្ពស់ ដែលមានសញ្ញាប័ត្រខ្ពស់ជាងបរិញ្ញាប័ត្រ ត្រូវបានតម្លើងថ្នាក់មួយថ្នាក់ជាស្វ័យប្រវត្តិ ។

**មាត្រា ១៨.-** សញ្ញាស័ក្តិ និងឯកសណ្ឋានសំរាប់មន្ត្រីការទូតជាន់ខ្ពស់ត្រូវកំណត់ដោយព្រះរាជក្រឹត្យមួយដោយឡែក។

## ជំពូកទី ៨

## អន្តរប្បញ្ញត្តិ

**មាត្រា ១៩.-** ចំនួនដំបូងនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ត្រូវកសាងចេញពីសមាហរណកម្មនៃមន្ត្រីរាជការទាំងឡាយដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ និងនៅស្ថានតំណាងនានា នៃព្រះរាជាណាចក្រកម្ពុជានៅបរទេស។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**មាត្រា ២០.-** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

Downloaded from http://www.khmerlaws.com

**មាត្រា ២១.** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

ភ្នំពេញ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

**ព្រះរាជក្រឹត្យ នស/រកត/០៤០១/០៨៦**

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្ម មាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា

Downloaded from http://www.khmerlaws.com